**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីវិជ្ជមានកូវីដ-១៩ ថ្មី ចំនួន ០២នាក់ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖**

គិតត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- **ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន ១២៩នាក់** (ស្មើនឹង ៩១,៤៩% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៣៩នាក់ និងប្រុស ៩០នាក់
- **អ្នកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យរដ្ឋ មានចំនួន ១២នាក់** (ស្ត្រី ០១នាក់ និងបុរស ១១នាក់)៖
    - បុរសជនជាតិខ្មែរ០៨នាក់ ស្ត្រីជនជាតិខ្មែរ០១នាក់ និងបុរសជនជាតិឥណ្ឌូនេស៊ី ០១នាក់ ដែលបានវិលត្រឡប់មកពីប្រទេសឥណ្ឌូណេស៊ីកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
    - បុរសជនជាតិខ្មែរ ០២នាក់ ដែលបានវិលត្រឡប់មកពីប្រទេសម៉ាឡេស៊ី កំពុងសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ
- **អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់នៅទូទាំងប្រទេស សរុបចំនួន ១៤១នាក់** (ស្ត្រី ៤០នាក់ និងបុរស ១០១នាក់)។

**២. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី** ចំនួន ០២នាក់ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០

- បុរសជនជាតិខ្មែរអាយុ ២៣ឆ្នាំ មានអាស័យដ្ឋាននៅភូមិអំពិល ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ និងបុរសជនជាតិខ្មែរអាយុ ១៥ឆ្នាំ មានអាស័យដ្ឋានភូមិព្រែកតាខ្មៅ ឃុំដើមមាន ខេត្តកណ្តាល ជាអ្នកធ្វើដំណើរវិលត្រឡប់មកពីប្រទេសម៉ាឡេស៊ី តាមជើងហោះហើរត្រង់ បានមកដល់កម្ពុជានៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ទទួលបានលទ្ធផលតេស្ត វិជ្ជមានវីរុសកូវីដ-១៩។ បច្ចុប្បន្ន អ្នកជំងឺទាំងពីរនាក់នេះ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

**សម្គាល់៖** ជើងហោះហើរនេះ មានអ្នកដំណើរសរុបចំនួន ១០៧នាក់ (ស្ត្រី ៣៨នាក់ និងបុរស ៦៩នាក់) ហើយក្នុងចំនួននេះមានជនជាតិខ្មែរចំនួន ១០៥នាក់ (ស្ត្រី ៣៦នាក់) និងជនជាតិម៉ាឡេស៊ីចំនួន ០២នាក់ (ស្ត្រី)។

អ្នកដំណើរជនជាតិខ្មែរចំនួន ១០៣នាក់ ដែលមានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ត្រូវបានបន្តស្នាក់នៅមណ្ឌលចត្តាឡីស័កជម្ពូវ័ន១ រាជធានីភ្នំពេញ (សម្រាប់អ្នកដែលមិនមានលទ្ធភាពបង់ថ្លៃសណ្ឋាគារ) ដើម្បីរងចាំការដឹកជញ្ជូនទៅបន្តធ្វើចត្តាឡីស័កនៅតាមបណ្តាខេត្តដែលពួកគាត់រស់


ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

នៅរៀងៗខ្លួន និងបុរសជនជាតិម៉ាឡេស៊ី ០២នាក់ បន្តស្នាក់នៅសណ្ឋាគារមួយក្នុងទីក្រុងភ្នំពេញ (សម្រាប់អ្នកដែលជ្រើសរើសយកការបង់ថ្លៃសណ្ឋាគារ) ធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ ដើម្បីតាមដានសុខភាពបន្តទៀត។

### ៣. ការក្រើនរំលឹកកិច្ចការពារខ្លួនពីការចម្លងវីរុសកូវីដ-១៩

អង្គការសុខភាពពិភពលោក បានបញ្ជាក់ហើយថា យើងមិនទាន់ដឹងបានអំពី វីរុសកូវីដ-១៩ នេះ មានអត្តចរិកបែបណា និងនៅកន្លែងណានៅឡើយ តែអ្វីដែលយើងអាចដឹងបាននោះ គឺការចម្លងរបស់វាបណ្ដាលមកពីការប៉ះពាល់ផ្ទាល់ទៅនឹងតំណក់ទឹកមាត់តូចៗ ឬទឹករំអិលផ្លូវដង្ហើមរបស់អ្នកមានផ្ទុកវីរុសកូវីដ-១៩ ហើយបុគ្គលមិនបានអនុវត្តន៍វិធានការការពារខ្លួនបានត្រឹមត្រូវ ជាពិសេស ហានិភ័យក្នុងការចម្លងវីរុសដ៏កាចសាហាវនេះ គឺមានខ្ពស់ នៅពេលដែលបុគ្គលចល័តធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ដោយភ្លេច ឬមិនបានអនុវត្តន៍វិធានការការពារខ្លួន។ ការចម្លងគឺអាចនឹងកើតមានឡើងសម្រាប់បុគ្គល នៅគ្រប់កាលទេសៈ គ្រប់ពេលវេលា និងគ្រប់ទីកន្លែង។

**ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល** សូមធ្វើការក្រើនរំលឹកអំពាវនាវហើយអំពាវនាវទៀត ជូនដល់បងប្អូនប្រជាពលរដ្ឋយើងទាំងអស់ ឲ្យបន្តកិច្ចការពារខ្លួនតាមការណែនាំរបស់ក្រសួងសុខាភិបាល កុំភ្លេចខ្លួនឲ្យសោះ ដោយត្រូវចេះផ្លាស់ប្ដូរទម្លាប់របស់ខ្លួនឲ្យស្របតាម *"ការរស់នៅធម្មតា តាមបែបគន្លងថ្មី"*។ ភាពធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩នេះ គឺយើងមិនត្រូវមើលរំលងនោះទេ ដោយវីរុសកូវីដ-១៩នេះ អាចវាយលុកផ្លូវដង្ហើមយ៉ាងសាហាវដែលធ្វើឲ្យមនុស្សពិបាកដកដង្ហើមណាស់ រហូតដល់គ្រុនរលាកសួតដោយខ្វះអុកស៊ីហ្សែន ឈានដល់ស្លាប់បាត់បង់ជីវិតបាន ដែលក្រុមគ្រូពេទ្យក៏ពិបាកនឹងជួយសង្គ្រោះឲ្យផុតពីសេចក្ដីស្លាប់នេះបានដែរ។ គ្រោះមរណៈ ដោយសារជំងឺកូវីដ-១៩ ស្ថិតនៅចំពោះមុខក្នុងស្ថានភាពគួរឲ្យមានការព្រួយបារម្ភណាស់នៅលើសាកលលោក នៅក្នុងតំបន់ នៅតាមបណ្ដាប្រទេស នៅតាមសហគមន៍ និងសម្រាប់បុគ្គល។ ដូច្នេះ សូមបងប្អូនប្រជាពលរដ្ឋយើង ជាពិសេសបុគ្គលគ្រប់រូប ត្រូវតែខិតខំបន្តកិច្ចការពារខ្លួនពីការចម្លងវីរុសដ៏កាចសាហាវនេះ ដើម្បីសុខភាពផ្ទាល់ខ្លួន ក្រុមគ្រួសារខ្លួន និងសហគមន៍របស់ខ្លួន គ្មានការចម្លងវីរុសកូវីដ-១៩។ សូមចូលរួមអនុវត្តន៍ការរស់នៅធម្មតា តាមបែបគន្លងថ្មី ជាមួយនឹងការអនុវត្តន៍កិច្ចការពារខ្លួនជាប់ជាប្រចាំឲ្យបានគ្រប់ៗគ្នា ដើម្បីជៀសផុតពីគ្រោះមរណៈ ដោយសារភាពធ្ងន់ធ្ងរនៃជំងឺដ៏កាចសាហាវនេះ។ ឯកឧត្តមរដ្ឋមន្ត្រី ក៏សូមថ្លែងអំណរគុណជាអនេកប្បការនូវរាល់ការចូលរួមទាំងអស់របស់លោកអ្នក ដើម្បីរួមគ្នាទប់ស្កាត់រលកទីពីរនៃការចម្លងវីរុសកូវីដ-១៩ នៅកម្ពុជា។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអាទិត្យ ៨កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**
រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា